ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ.០១៩...សសរ.../គ.ជ.អ.ប

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតនិងការប្រព្រឹត្តទៅរបស់ក្រុមការងារសេវាសង្គមថ្នាក់ជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជា
## ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ.នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខនស/រកត/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៤២៧៥ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងសេចក្តីណែនាំលេខ០៨២ សណន/គ.ជ.រ.រ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក)
- ផ្អែកតាមការចាំបាច់របស់ គ.ជ.អ.ប

## សម្រេច

**ប្រការ ១.-**

ត្រូវបង្កើតក្រុមការងារមួយ ដែលមានឈ្មោះថា "**ក្រុមការងារ សេវាសង្គមថ្នាក់ជាតិ**" ហៅកាត់ថា **ក.ស.ជ**។

**ប្រការ ២.-**

ក្រុមការងារសេវាសង្គមថ្នាក់ជាតិមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **សត់ សេដ្ឋា** | ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប | ប្រធាន |
| ២. | ឯកឧត្តម **លេខ ទី** | អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប | អនុប្រធាន |
| ៣. | លោកស្រី **គឹម ស៊ីផាត់** | អគ្គនាយករង ក្រសួងកិច្ចការនារី | អនុប្រធាន |
| ៤. | លោក **យិន ម៉ាលីណា** | ប្រធាននាយកដ្ឋានរដ្ឋបានមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិកអចិន្ត្រៃយ៍ |
| ៥. | លោកស្រី **ខៀវ ម៉ូរី** | អគ្គលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៦. | លោកស្រី **យឹម ចាន់ស្រី** | ប្រធាននាយកដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧. | លោក **ហួ ឈុនត្រី** | អនុប្រធាននាយកដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨. | លោក **ខោល យុទ្ធលី** | អនុប្រធាននាយកដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៩. | លោក **តែ ឈុនហាក់** | អនុប្រធាននាយកដ្ឋាន ក្រសួងកិច្ចកានារី | សមាជិក |
| ១០. | លោកស្រី **ឡាច សាម៉ន** | អនុប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១. | លោក **សេត សាម៉ន** | អនុប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២. | លោក **តូច ចាន់នី** | អនុប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៣. | លោក **សយ កុសល** | ប្រធានសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាឃុំ សង្កាត់ | សមាជិក |
| ១៤. | លោក **សេខ សីលា** | ប្រធានការិយាល័យ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៥. | លោក **សុខ សុទ្ធី** | ប្រធានការិយាល័យ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៦. | លោក **គួយ ម៉ិយ** | អនុប្រធានការិយាល័យ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៧. | លោក **ជេដ្ឋ គឹមជុន** | អនុប្រធានការិយាល័យ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៨. | កញ្ញា **ផាន់ សុគំគ្រា** | មន្ត្រីផ្នែករដ្ឋបាល និងលទ្ធកម្មនៃលេខាធិការដ្ឋាន គ.ជ.អ.ប | សមាជិក |
| ១៩. | កញ្ញា **ទន ស្រីមុំ** | មន្ត្រីអង្គភាពគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប | សមាជិក |
| ២០. | កញ្ញា **ប៉ែន សារ៉ែន** | មន្ត្រីនាយកដ្ឋានបុគ្គលិក ក្រសួងសុខាភិបាល | សមាជិក |
| ២១. | លោកស្រី **សឿន សាវី** | មន្ត្រីមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ក្រសួងសុខាភិបាល | សមាជិក |
| ២២. | លោក **គោគ សំអាត** | មន្ត្រីផ្នែកគ្រប់គ្រងកិច្ចសន្យា លេខាធិការដ្ឋាន គ.ជ.អ.ប | សមាជិក |

**ប្រការ ៣.-**

ក្រុមការងារសេវាសង្គមថ្នាក់ជាតិ មានតួនាទីផ្តល់យោបល់ដល់ គ.ជ.អ.ប ក្នុងការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីជំរុញ ពង្រឹង សម្របសម្រួល និងតាមដានវាយតម្លៃការអនុវត្តមុខងារនានា ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈផ្នែកសង្គម ការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅមូលដ្ឋាន ។

**ប្រការ ៤.-**

ក្រុមការងារសេវាសង្គមថ្នាក់ជាតិមានភារកិច្ចជួយ គ.ជ.អ.ប តាមរយៈលេខាធិការដ្ឋាន គ.ជ.អ.ប លើកិច្ចការដូចខាងក្រោម :

- រៀបចំផែនការសកម្មភាពរបស់ ក.ស.ជ
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងកិច្ចប្រជុំវិសាមញ្ញរបស់ ក.ស.ជ
- ជួយក្រសួង ស្ថាប័នដែលជាសមាជិកក្រុមការងារសេវាសង្គមថ្នាក់ជាតិក្នុងការរៀបចំផែនការសកម្មភាព និងផែនការថវិកាសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ
- ចូលរួមរៀបចំគោលការណ៍ សេចក្តីណែនាំ និងឯកសារបណ្តុះបណ្តាលទាក់ទងនឹងការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា អំពីការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ
- ផ្តល់យោបល់ និងគាំទ្រលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការអនុវត្តផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ដែលពាក់ព័ន្ធនឹងការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ
- គាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងអនុវត្តមុខងាររបស់ខ្លួន និងសកម្មភាពនានាដែលពាក់ព័ន្ធនឹងការលើកកម្ពស់សេវាសង្គមផ្នែកសុខភាពមាតា មត្តេយ្យសិក្សា សហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

- តាមដានការអនុវត្តគោលការណ៍ និងសេចក្តីណែនាំនានាពាក់ព័ន្ធនឹងការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នដែលជាសមាជិករបស់ក្រុមការងារសេវាសង្គមថ្នាក់ជាតិ ក្នុងការពង្រឹងបណ្តាញការងារ និងការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ផ្តល់យោបល់ដល់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការរៀបចំ និងគាំទ្រដល់ក្រសួង និងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ
- លើកសំណើ និងផ្តល់យោបល់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប អំពីបញ្ហាសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ ដើម្បីរៀបចំគោលការណ៍ និងសេចក្តីណែនាំ
- រៀបចំ និងចងក្រងព័ត៌មាន និងបទពិសោធន៍ទាក់ទងនឹងការផ្ទេរមុខងារផ្នែកសេវាសង្គមដែលបានផ្ទេរទៅឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងចែករំលែកព័ត៌មាន និងបទពិសោធន៍ទាំងនេះដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា
- បំពេញភារកិច្ចផ្សេងៗទៀតទាក់ទងនឹងការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។

**ប្រការ ៥.-**

ប្រធាន ក.ស.ជ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ជាអធិបតីនៃកិច្ចប្រជុំ ដឹកនាំ និងសម្របសម្រួលរាល់កិច្ចប្រជុំរបស់ ក.ស.ជ
- ដឹកនាំ ណែនាំ តម្រង់ទិស និងសម្របសម្រួលការអនុវត្តការងាររបស់ក្រុមការងារសេវាសង្គមថ្នាក់ជាតិ ដើម្បីជំរុញឱ្យក្រុមការងារសេវាសង្គមថ្នាក់ជាតិបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព
- បែងចែកភារកិច្ចដល់សមាជិក ក.ស.ជ
- សម្របសម្រួល ប្រាស្រ័យទាក់ទង និងសហការជាមួយក្រសួង ស្ថាប័នដែលជាសមាជិក ក.ស.ជ និងស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងរកការគាំទ្រ និងការសហការ
- ដឹកនាំ និងសម្របសម្រួលក្រុមការងារសេវាសង្គមថ្នាក់ជាតិ ក្នុងការរៀបចំគោលការណ៍ សេចក្តីណែនាំ និងឯកសារបណ្តុះបណ្តាលទាក់ទងនឹងការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ ព្រមទាំងការបណ្តុះបណ្តាលដល់ក្រុមការងារសេវាសង្គមថ្នាក់ជាតិ ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា
- រាយការណ៍អំពីការងាររបស់ក្រុមការងារសេវាសង្គមថ្នាក់ជាតិជូន គ.ជ.អ.ប។

**ប្រការ ៦.-**

អនុប្រធាន ក.ស.ជ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- បំពេញការងារជំនួសប្រធាន ក.ស.ជ នៅពេលដែលប្រធានអវត្តមាន តាមការផ្ទេរសិទ្ធិ ពីប្រធាន
- ចូលរួមរាល់កិច្ចប្រជុំរបស់ ក.ស.ជ
- ផ្តល់យោបល់ដល់ប្រធានទាក់ទងនឹងការងាររបស់ ក.ស.ជ
- ពិនិត្យរបាយការណ៍ និងឯកសារនានារបស់ក្រុមការងារសេវាសង្គមថ្នាក់ជាតិ មុននឹងដាក់ជូនប្រធាន ក.ស.ជ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីប្រធាន ក.ស.ជ ។

**ប្រការ ៧.-**

សមាជិកអចិន្ត្រៃយ៍របស់ ក.ស.ជ មានតួនាទី និងភាកិច្ចដូចខាងក្រោម :

- រៀបចំ និងចាត់ចែងការងាររដ្ឋបាល ការងារទំនាក់ទំនង និងកិច្ចប្រជុំរបស់ ក.ស.ជ
- ចែកជូនរបាយការណ៍ ឯកសារនានា និងចែករំលែកព័ត៌មានដល់សមាជិក ក.ស.ជ និងអ្នកពាក់ព័ន្ធនានា
- ជួយប្រធាន ក.ស.ជ ក្នុងការរៀបចំគោលការណ៍ សេចក្តីណែនាំ និងឯកសារបណ្តុះបណ្តាលទាក់ទងនឹងការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និង កិច្ចការពារកុមារ
- រៀបចំរបាយការណ៍ និងឯកសារនានារបស់ ក.ស.ជ ជាប្រចាំ និងទៀងទាត់ ដើម្បីដាក់ជូនប្រធានក្រុមការងារ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីប្រធាន ក.ស.ជ ។

**ប្រការ ៨.-**

សមាជិក ក.ស.ជ មានតួនាទី និងភាកិច្ចដូចខាងក្រោម :

- ចូលរួមរាល់កិច្ចប្រជុំរបស់ក្រុមការងារសេវាសង្គមថ្នាក់ជាតិ
- ចែករំលែកព័ត៌មានដល់ក្រុមការងារសេវាសង្គមថ្នាក់ជាតិ អំពីគោលនយោបាយរបស់ក្រសួង ស្ថាប័នសាមីទាក់ទងនឹងក្នុងការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និង កិច្ចការពារកុមារ
- ចូលរួមផ្តល់យោបល់លើការរៀបចំគោលការណ៍ សេចក្តីណែនាំ និងឯកសារបណ្តុះបណ្តាលទាក់ទងនឹងការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ
- ចូលរួមផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានាអំពីការលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និង កិច្ចការពារកុមារ

- បង្កើនការប្រាស្រ័យទាក់ទង និងកិច្ចសហការរវាងក្រសួង ស្ថាប័នរបស់ខ្លួនជាមួយនឹង ក.ស.ជ
- ជំរុញ និងណែនាំដល់មន្ទីរ ការិយាល័យ អង្គភាពខ្សែបណ្តោយរបស់ខ្លួន ដែលប្រចាំនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការគាំទ្រដល់ការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ
- រាយការណ៍អំពីការងាររបស់ ក.ស.ជ ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន ក.ស.ជ ។

**ប្រការ ៩.-**

ក្រុមការងារសេវាសង្គមថ្នាក់ជាតិ មានរបៀបរបបធ្វើការងាររបស់ខ្លួន ដូចខាងក្រោម :

- ត្រូវរៀបចំប្រជុំត្រីមាស ប្រជុំឆមាស និងប្រចាំឆ្នាំរបស់ខ្លួនជាទៀងទាត់ និងអាច រៀបចំកិច្ចប្រជុំវិសាមញ្ញ តាមការស្នើសុំរបស់ប្រធាន ឬការស្នើសុំពីសមាជិកចំនួនលើសពីពាក់កណ្តាលនៃសមាជិកទាំងមូល ។
- គ្រប់កិច្ចប្រជុំរបស់ ក.ស.ជ ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់ប្រធាន ក.ស.ជ ។ ក្នុងករណីប្រធាន ក.ស.ជ អវត្តមាន ប្រធានត្រូវចាត់តាំងអនុប្រធានមួយរូបជាតំណាង ដើម្បីដឹកនាំការប្រជុំ ។
- ក្នុងករណីចាំបាច់ ក.ស.ជ អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធដែលមិនមែនជាសមាជិក ក.ស.ជ តំណាងអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួនបាន ។
- លិខិតអញ្ជើញចូលរួមប្រជុំ ត្រូវផ្ញើជូនសមាជិក ក.ស.ជ យ៉ាងតិចបី (០៣) ថ្ងៃការងារមុនថ្ងៃប្រជុំ ។

លិខិតអញ្ជើញប្រជុំទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវរបៀបវារៈនៃកិច្ចប្រជុំ និងឯកសារនានាដែលពាក់ព័ន្ធសម្រាប់កិច្ចប្រជុំ និងសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន ។

- គ្រប់កិច្ចប្រជុំត្រូវមានកំណត់ហេតុនៃអង្គប្រជុំ ។ ប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំដោយភ្ជាប់ជាមួយបញ្ជីវត្តមាន ត្រូវប្រគល់ជូនសមាជិកគ្រប់រូបនៃ ក.ស.ជ និងផ្ញើជូនទៅក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា ។

**ប្រការ ១០.-**

រាល់ការសម្រេចចិត្តនានារបស់ ក.ស.ជ ត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំរបស់ ក.ស.ជ ។ សេចក្តីសម្រេចចិត្តរបស់អង្គប្រជុំអាចយកជាការបានលុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃសមាជិក ក.ស.ជ ទាំងមូល ។

ក្នុងករណី ការអនុម័តមានសម្លេងស្មើគ្នា សម្លេងប្រធានអង្គប្រជុំមានឧត្តមានុភាព ។

**ប្រការ ១១.-**

រៀងរាល់បីខែម្តង ក្រុមការងារសេវាសង្គមថ្នាក់ជាតិ ត្រូវធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងាររបស់ខ្លួនជូន គ.ជ.អ.ប និងចម្លងជូនក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានាតាមការចាំបាច់។

**ប្រការ ១២.-**

សមាជិក សមាជិកានៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ អនុគណៈកម្មាធិការ គ.ជ.អ.ប លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នជាសមាជិកនៃ គ.ជ.អ.ប ឯកឧត្តម លោកជំទាវ លោក លោកស្រីដូចមានរាយនាមក្នុងប្រការ៣ខាងលើ និងភាគីពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី..២៨..ខែ..មីនា..ឆ្នាំ ២០១០*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

ស ខេង

**<u>កន្លែងទទួល</u> :**

- *លេខាធិការដ្ឋាន គ.ជ.អ.ប*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *រដ្ឋបាលថ្នាក់ក្រោមជាតិ*
- *ក្រុមប្រឹក្សាឃុំ សង្កាត់*
- *ដៃគូអភិវឌ្ឍន៍នានា*

  *"<u>ដើម្បីជូនជ្រាប</u>"*
- *ដូចប្រការ ៣ (<u>ដើម្បីអនុវត្ត</u>)*
- *ឯកសារ - កាលប្បវត្តិ*